ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលកិច្ចប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី ស្តីពីការពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះសាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា នៅទីស្តីការក្រសួង កាលពីព្រឹកថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ មានបើកកិច្ចប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី ស្តីពីការពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧ ដោយមានការចូលរួមពីតំណាងកម្មករនិយោជិតចំនួន១៦រូប តំណាងនិយោជកចំនួន១៦រូប និងតំណាងរាជរដ្ឋាភិបាលចំនួន១៦រូប។ ដោយឡែក នៅរសៀលថ្ងៃដដែល ក្រុមការងារបច្ចេកទេសភាគីរាជរដ្ឋាភិបាលក៏បានជួបប្រជុំជាលក្ខណៈទ្វេភាគីជាមួយក្រុមការងារបច្ចេកទេសភាគីកម្មករនិយោជិត (សហជីព)។ កិច្ចប្រជុំទាំង២នេះ សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

១-បានរៀបចំក្រមសីលធម៌សម្រាប់អនុវត្តក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា និងបានស្តាប់ឡើងវិញនូវបទបង្ហាញស្តីពីលក្ខណវិនិច្ឆ័យ និងរូបមន្តក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង នៅកម្ពុជា។

២-បានបញ្ជាក់ពីគោលជំហរផ្លូវការរបស់ភាគីនីមួយៗ ចំពោះមុខគ្នា ជាមួយនឹងហេតុផលបឋមក្នុងការសម្រេចយកតួលេខរបស់ភាគីនីមួយៗ។

៣-ក្រសួងបានរៀបចំបន្ទប់ប្រជុំចំនួន២ ដែលមានសម្ភារការិយាល័យ កុំព្យូទ័រ ព្រីនធ័រ និងភេសជ្ជៈ សម្រាប់ភាគីកម្មករនិយោជិត និងភាគីនិយោជក ប្រើប្រាស់សម្រាប់ប្រជុំផ្ទៃក្នុង និងប្រជុំទ្វេភាគី ចាប់ពីថ្ងៃនេះរហូតដល់ថ្ងៃប្រជុំសម្រេច។

៤-បានកំណត់យកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ សម្រាប់ប្រជុំពិភាក្សាលម្អិត ជាលក្ខណៈត្រីភាគី។

៥-បានស្តាប់នូវសំណូមពរ និងតម្រូវការរបស់ភាគីកម្មករនិយោជិត និងបានយល់គ្នាទៅវិញទៅមកបន្ថែមទៀតអំពីគោលបំណងរួមរបស់រាជរដ្ឋាភិបាល ដែលជាទូទៅគឺដូចគ្នាទៅនឹងគោលបំណងរបស់ភាគីកម្មករនិយោជិតដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩